
ការស្វែងយល់អំពីជីវិត
តើការទៅព្រះវិហារ
មានន័យថា
ខ្ញុំជាគ្រីស្ទបរិស័ទឬ?
Does going to church
mean I am a Christian?

**កាលពីក្មេង ឪពុកម្ដាយខ្ញុំបាននាំខ្ញុំទៅព្រះវិហារ។** ខ្ញុំបានលេងល្បែងកម្សាន្ត នៅក្នុងសាលារៀនថ្ងៃអាទិត្យ ហើយក៏បានច្រៀងចម្រៀងកាយវិការជាច្រើនបទ មុនពេលខ្ញុំចូលរួមជាមួយក្រុមយុវជនសកម្ម ដែលជាក្រុមធំជាងក្រុមកុមារ ពេលខ្ញុំចូលដល់វ័យជំទង់។ កាលនោះលោកស្ទីវ ដែលជាអ្នកដឹកនាំក្រុមមានគំនិតល្អៗជាច្រើន សម្រាប់ក្រុមយុវជន ហើយបាននាំមកនូវភាពអ៊ូអរ និងរីករាយ។

កាលណាយើងនាំមិត្តភក្តិកាន់តែច្រើន មកចូលរួមកម្មវិធី នោះយើងក៏ឈ្នះរង្វាន់កាន់តែច្រើនផងដែរ។ ខ្ញុំមិនដែលមានការសង្ស័យទាំងស្រុងថា ព្រះគម្ពីរជាសេចក្ដីពិតឬអត់។ គេមិនបានលាងខួរខ្ញុំឲ្យជឿព្រះគម្ពីរ ដោយគ្មានការគិតពិចារណានោះឡើយ។ ខ្ញុំគ្រាន់តែគិតថា មានតែការបង្រៀននៅក្នុងព្រះគម្ពីរទេ ដែលអាចឆ្លើយតបយ៉ាងសមហេតុផល ចំពោះសំណួរធំៗ អំពីជីវិត។ ខ្ញុំបានឆ្លងកាត់ភាពប្រែប្រួល និងដំណាក់កាលខុសៗគ្នា ក្នុងវ័យជំទង់ តែខ្ញុំជាអ្នកចូលរួមទៀងទាត់ជាងគេ ក្នុងកម្មវិធីយុវជនពេលល្ងាចថ្ងៃពុធ។ ខ្ញុំថែមទាំងបាននិយាយអំពីព្រះយេស៊ូវ ប្រាប់មិត្តភក្តិខ្ញុំទៀតផង។ ពួកគេមានសំណួរជាច្រើន ហើយខ្ញុំបានឆ្លើយសំណួរ ដោយមោទនភាព តាមចំណេះដឹងក្នុងព្រះគម្ពីរ។

តែខ្ញុំក៏មានចំណុចអវិជ្ជមានផងដែរ។ ខ្ញុំស្រឡាញ់រូបសម្រស់របស់ខ្ញុំ។ ខ្ញុំមានការងប់ងល់នឹងរូបសម្បត្តិ និងសុភមង្គលរបស់ខ្ញុំ។ ក្មេងប្រុសនីមួយៗ ដែលខ្ញុំបានឃើញ គឺសុទ្ធតែអាចធ្វើជាមិត្តប្រុសខ្ញុំ ឬគ្មានតម្លៃអ្វីសោះសម្រាប់ខ្ញុំ។ ខ្ញុំបានស្រមើស្រមៃអំពីរឿងផ្លូវភេទជាប់ជានិច្ច។

*ការរស់នៅជាក្មេងជំទង់ និងការចូលរួមក្នុងព្រះវិហារ មានការលំបាក។ មានការជាច្រើន ដែលគេរំពឹងថា យើងគួរធ្វើ ឬមិនគួរធ្វើ ដែលនាំឲ្យយើងមានការភាន់ច្រឡំជាញឹកញាប់។ ហើយពិភពខាងក្រៅ មានរឿងដែលរំភើបរីករាយជាច្រើន ដែលយើងចង់រុករក។*

បើសិនជាអ្នកកំពុងតែមានការពិបាក ក្នុងផ្លូវអារម្មណ៍ នៅព្រះវិហារ ហើយថែមទាំងបានព្យាយាមស្វែងយល់ អំពីអត្ថន័យដ៏ពិត នៃជីវិតជាគ្រីស្ទបរិស័ទ ខ្ញុំសង្ឃឹមថា រឿងរបស់ខ្ញុំនឹងលើកទឹកចិត្តអ្នក និងជួយឲ្យអ្នកគិតអំពីជំហានបន្ទាប់ នៅក្នុងដំណើរជីវិតរបស់អ្នក។


ការដើរផ្លូវពីរ
ក្នុងពេលតែមួយ

*កុំឲ្យស្រឡាញ់លោកីយ៍ ឬរបស់អ្វីដែលនៅក្នុងលោកីយ៍នេះឲ្យសោះ បើអ្នកណាស្រឡាញ់លោកីយ៍ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ។ ដ្បិតអស់ទាំងសេចក្តី ដែលនៅក្នុងលោកីយ៍នេះ គឺជាសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត នោះមិនកើតមកពីព្រះវរបិតាទេ គឺមកតែពីលោកីយ៍នេះវិញ។ ១យ៉ូហាន ២:១៥-១៦*

**ដើម្បីរស់នៅជាគ្រីស្ទបរិស័ទពិតប្រាកដ** មនុស្សម្នាក់ៗត្រូវមានការប្រកបទាក់ទងជាមួយព្រះយេស៊ូវ ដោយផ្ទាល់ៗខ្លួន។ យើងមិនអាចពឹងផ្អែកទៅលើជំនឿរបស់ឪពុកម្តាយ ឬមិត្តភក្តិយើងនោះឡើយ។ ខ្ញុំបានដឹង អំពីរឿងពិតនេះ ពេលខ្ញុំមានអាយុ១៧ឆ្នាំ។ កាលនោះ ខ្ញុំកំពុងតែស្ថិតក្នុងការណាត់ជួបជាមួយមនុស្សប្រុស ដ៏គួរឲ្យទាក់ទាញម្នាក់។ ខ្ញុំមិនមានចិត្តស្រឡាញ់គាត់ពិតប្រាកដទេ ប៉ុន្តែ គាត់ចូលចិត្តខ្ញុំ ហើយខ្ញុំគិតថា គ្រាន់តែចូលចិត្តខ្ញុំ គឺគ្រប់គ្រាន់ហើយ។ គាត់មានអាយុបងខ្ញុំមួយឆ្នាំ ហើយមានម៉ូតូជិះ។ គាត់ជាមនុស្សរៀន តែមានបទពិសោធន៍ក្នុងសង្គម ហើយការដែលខ្ញុំបាននៅក្បែរគាត់ គឺបានធ្វើឲ្យខ្ញុំចូលក្នុងចំណោមគេ យ៉ាងងាយស្រួល។ គាត់មានលក្ខណៈសម្បត្តិដែលត្រូវនឹងការស្រមើស្រមៃរបស់ខ្ញុំ។

ខ្ញុំនៅចាំថា ថ្ងៃមួយ ខ្ញុំបានទៅលេងផ្ទះមិត្តភក្តិម្នាក់ ក្នុងអំឡុងពេលនោះ។ នាងជាកូនស្រីរបស់គ្រូគង្វាល។ នាងបានយកសៀវភៅកត់ត្រាការអធិស្ឋានប្រចាំថ្ងៃ មកឲ្យខ្ញុំមើល។ នាងបានដាក់សៀវភៅនោះជាប់ជាមួយព្រះគម្ពីរ យ៉ាងមានរបៀប នៅលើតុ នៅចំហៀងគ្រែគេងរបស់នាង ដោយមានប៊ិចពិសេសមួយដើម និងស្នៀតសៀវភៅមួយ។ ខ្ញុំបានឃើញបញ្ជីសំណូមពរអធិស្ឋានរបស់នាង ដែលព្រះទ្រង់បានឆ្លើយតប ហើយខ្ញុំក៏បានឆ្ងល់ថា ហេតុអ្វីបានជានាងខ្វល់អំពី សៀវភៅកត់ត្រាការអធិស្ឋានឡប់ៗ ខណៈពេលដែលនាងជាក្មេងអាយុ១៧ឆ្នាំ ដែលមានពិភពលោកទាំងមូល នៅខាងក្រៅ កំពុងតែរង់ចាំ ឲ្យនាងទៅរុករក។ កាលនោះ ខ្ញុំយល់ឃើញថា គ្រីស្ទបរិស័ទដទៃទៀតបាននិយាយអំពី "លោកិយ" ធ្វើមើលតែលោកិយនោះ ធំណាស់ តែពួកគេមិនបានចូលក្នុងចំណោមគេ ក្នុងលោកិយនេះ ឲ្យបានល្អដូចខ្ញុំទេ។ ទោះជាយ៉ាងណាក៏ដោយ ពេលដែលខ្ញុំកំពុងតែឈរកាន់សៀវភៅកត់ត្រាការអធិស្ឋានរបស់មិត្តភក្តិខ្ញុំ ខ្ញុំស្រាប់តែមានអារម្មណ៍ថា ខ្មាស់នាង។ វាជាពេលដ៏សំខាន់ក្នុងជីវិតខ្ញុំ។ ខ្ញុំក៏បានដឹងថា តាមពិតខ្ញុំបានស្រឡាញ់លោកិយ ខ្លាំងជាងព្រះយេស៊ូវ។


ការវិលត្រឡប់
មករកព្រះវិញ

**ខ្ញុំ និងបងប្រុសខ្ញុំបានរក្សាទុកនូវស្រាបៀរថោកៗជាច្រើន** នៅក្នុងបន្ទប់ក្រោមដីរបស់យើង។ ពេលណាឪពុកម្ដាយយើងមិននៅផ្ទះ យើងបានហៅមិត្តភក្តិយើងមកផឹកស៊ី ស្រែកឡូឡា ប្រើពាក្យអសុរោះ និងធ្វើរឿងជាច្រើន ដែលគ្រីស្ទបរិស័ទមិនគួរធ្វើ។ ខ្ញុំថែមទាំងធ្លាប់លួចចេញក្រៅផ្ទះ នៅពេលយប់ ពេលដែលអ្នកផ្ទះគេងលក់អស់។ ខ្ញុំក៏បានទៅជួបមិត្តភក្តិខ្ញុំ ដើម្បីធ្វើអ្វីដែលយើងអាចធ្វើទៅរួច ដោយមិនខ្វល់អំពីការណែនាំ ដែលខ្ញុំបានទទួលនៅព្រះវិហារ។

ទោះខ្ញុំបានបង្ហាញសេចក្ដីជំនឿ និងអធិស្ឋានលន់តួបាបឲ្យគេឃើញច្រើនប៉ុណ្ណា ហើយមានចំណេះដឹងក្នុងព្រះគម្ពីរច្រើនយ៉ាងណាក្ដី ក៏នៅតែមិនអាចបិទបាំងការពិត ដែលថា ខ្ញុំចូលចិត្តធ្វើអ្វីៗតាមទំនើងចិត្តខ្ញុំ ហើយរស់នៅ ដើម្បីតែខ្លួនឯង។

ខ្ញុំជឿអស់ពីចិត្តថា ព្រះយេស៊ូវគឺជាព្រះពិត តែខ្ញុំមិនចង់ដើរតាមព្រះអង្គទេ។

នៅពេលព្រឹកមួយ បន្ទាប់ពីខ្ញុំបាននៅជាមួយមិត្តប្រុសខ្ញុំបានមួយយប់ ខ្ញុំបានក្រោកឡើង ដោយមានអារម្មណ៍ថា ពិភពលោកហាក់ដូចជាជាប់គាំងលែងវិលទៅមុខទៀត។ ពេលវេលាហាក់ដូចជានៅទ្រឹងមួយកន្លែង ហើយខ្ញុំគ្មានសល់អ្វីសោះ គឺមានតែខ្លួនឯង និងព្រះជាម្ចាស់។ ពេលនោះ ខ្ញុំកំពុងតែមានការគិតពិចារណាដែលគួរឲ្យតក់ស្លត់បំផុត ក្នុងជីវិតខ្ញុំ។ ខ្ញុំគិត*ថា ខ្ញុំនឹងធ្លាក់នរកហើយ ព្រោះខ្ញុំសមនឹងធ្លាក់នរកមែន។*

គឺនៅពេលនោះហើយ ដែលខ្ញុំបានសម្រេចចិត្តងាកបែរមកព្រះជាម្ចាស់វិញ។ កន្លងមក ខ្ញុំមិនបានសម្រេចចិត្តថ្វាយជីវិត ហើយដើរតាមព្រះអង្គមួយរយភាគរយឡើយ ទោះខ្ញុំបានស្គាល់ព្រះអង្គ បានយល់ការបង្រៀន ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គយ៉ាងណាក្ដី។ ខ្ញុំក៏ឈប់គិតថា ការរស់នៅតាមលោកិយ ជាការរស់នៅដ៏ត្រឹមត្រូវទៀតហើយ ហើយទីបំផុតខ្ញុំក៏មានគំនិតយល់ស្រប ចំពោះព្រះជាម្ចាស់ ដោយទទួលស្គាល់ថា តាមពិត ខ្ញុំបានរស់នៅតាមភាពអាត្មានិយម និងអំពើបាបដ៏គ្រោះថ្នាក់ ហើយសក្តិសមនឹងទទួលការជំនុំជម្រះ។ ខ្ញុំមិនបានរស់នៅជាកម្មសិទ្ធិរបស់ព្រះអង្គទេ។ ខ្ញុំគ្រាន់តែមានចំណែកនៅក្នុងពួកជំនុំ តែមិនបានរស់នៅជាគ្រីស្ទបរិស័ទពិតប្រាកដ។


ការផ្លាស់ប្រែ
THE
CHANGE

**ការផ្លាស់ប្តូរដែលខ្ញុំបានសង្កេតឃើញភ្លាមៗ** គឺមាននៅក្នុងការស្រមៃរបស់ខ្ញុំ។ ខ្ញុំក៏បានឈប់មានការស្រមើស្រមៃដ៏ត្រេកត្រអាលទៀត។ ចាប់តាំងពីពេលនោះមក ពេលណាគំនិតខ្ញុំអណ្តែតអណ្តូងទៅរកការអ្វីដែលមិនត្រឹមត្រូវ ខ្ញុំក៏ត្រូវបានទាញនាំមកវិញភ្លាមដូចខ្សែភ្លើងឆក់។ ខ្ញុំមានអារម្មណ៍ថា ចិត្ត និងវិញ្ញាណខ្ញុំស្អាត គឺមិនប្រទ្បាក់ប្រទ្បូកដូចមុនទៀត។ គំនិតខ្ញុំចង់តែផ្តោតទៅលើព្រះយេស៊ូវ ហើយខ្ញុំក៏បានមើលឃើញលោកិយ តាមរបៀបដ៏ថ្មីស្រទ្បាងមួយ។

ពេលដែលយើងទុកចិត្តព្រះយេស៊ូវហើយ គឺមិនមានន័យថា យើងនឹងឈប់តយុទ្ធនឹងអំពើបាបនោះទ្បើយ តែព្រះអង្គនឹងជួយយើង ឲ្យកែប្រែអាកប្បកិរិយាចំពោះអំពើបាប និងការឈឺចាប់ ដែលបណ្តាលមកពីភាពអាត្មានិយម។ ខ្ញុំធ្លាប់ឮគ្រូអធិប្បាយម្នាក់ មានប្រសាសន៍ថា មនុស្សមានបាបរត់ចូលក្នុងអំពើបាប ហើយស្រទ្បាញ់អំពើបាប តែរាស្រ្តរបស់ព្រះធ្លាក់ចូលក្នុងអំពើបាប ហើយស្អប់អំពើបាប។ យើងរាល់គ្នា សុទ្ធតែមានការតយុទ្ធរៀងៗខ្លួន ប៉ុន្តែ កាលខ្ញុំនៅក្នុងវ័យក្មេងជំទង់ ខ្ញុំបានទទួលការបង្រៀនថា

*"បើអ្នកណាស្រទ្បាញ់លោកីយ៍ អ្នកនោះគ្មានសេចក្តីស្រទ្បាញ់*
*របស់ព្រះវរបិតានៅក្នុងខ្លួនទ្បើយ"។*

ទីបំផុត យើងត្រូវសម្រេចចិត្តថា យើងនឹងរស់នៅ សម្រាប់តែខ្លួនឯង ឬសម្រាប់ព្រះ។ ការនេះមិនមានន័យថា យើងនឹងមិនជំពប់ដួល ឬធ្វើខុស បន្ទាប់ពី យើងបានសម្រេចចិត្តរស់នៅថ្វាយព្រះហើយនោះទ្បើយ។ ប៉ុន្តែ អ្នកដែលជាកម្មសិទ្ធិរបស់ព្រះ គឺពិតជាចង់ឲ្យព្រះបន្តកែប្រែពួកគេ ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដើម្បីឲ្យពួកគេអាចមានលក្ខណៈកាន់តែដូចព្រះយេស៊ូវ។


គ្រោះថ្នាក់
នៅក្នុង
ការរស់នៅជា
គ្រីស្ទបរិស័ទ

**មានគ្រោះថ្នាក់ជាច្រើនអាចកើតមាន** នៅក្នុងការចម្រើនវ័យធំឡើង ក្នុងជីវិតជាគ្រីស្ទបរិស័ទ។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ អ្វីដែលគួរឲ្យខ្លាចបំផុតនោះ គឺនៅពេលដែលយើងគិតថា យើងបានសង្គ្រោះហើយ តែតាមពិត យើងមិនទាន់បានទទួលសេចក្តីសង្គ្រោះទេ។ ខ្ញុំមិនចង់បន្លាចអ្នកទេ តែខ្ញុំគ្រាន់តែចង់ផ្តល់យោបល់ខ្លះៗ ដល់អ្នក។ ព្រះគម្ពីរបានចែងច្បាស់ថា "បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត"(រ៉ូម ១០:៩)។ ប៉ុន្តែ ការសម្រេចចិត្តនេះ នឹងធ្វើឲ្យជីវិតយើងផ្លាស់ប្រែ។ វានឹងនាំឲ្យយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដែលក្នុងនោះ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ សម្រេចព្រះទ័យយាងចូលគង់ក្នុងយើង! ហេតុនេះហើយ ព្រះគម្ពីរបានប្រាប់យើងឲ្យឆែកពិនិត្យខ្លួនយើង គឺដូចដែលសាវ័កប៉ុលបានមានប្រសាសន៍ថា "ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល តើស្ថិតនៅក្នុងសេចក្តីជំនឿឬទេ ចូរល្បងខ្លួនមើលចុះ តើអ្នករាល់គ្នាមិនយល់ឃើញថា ព្រះយេស៊ូវគ្រីស្ទគង់ក្នុងអ្នករាល់គ្នាទេឬអី លើកតែអ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ"។ ហើយលោកយ៉ូហានក៏បានមានប្រសាសន៍ផងដែរថា "យើងរាល់គ្នាដឹងថា យើងស្គាល់ទ្រង់ ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តរបស់ទ្រង់"(១យ៉ូហាន ២:៣)។ បើយើងមិនមានទំនាក់ទំនងដែលសកម្ម និងរស់រវើកជាមួយព្រះទេ នោះយើងចាំបាច់ត្រូវឆែកមើលខ្លួនយើង ឲ្យដឹងថា យើងកំពុងតែរស់នៅដើម្បីអ្វី ឬដើម្បីនរណា?

បើសិនជាខ្ញុំមិនខិតខំពិនិត្យមើលខ្លួនឯង ជាមួយព្រះជាម្ចាស់ ឲ្យបានដិតដល់ទេ ខ្ញុំប្រហែលជាបន្តរស់នៅ ដោយគិតថា ខ្ញុំជាគ្រីស្ទបរិស័ទ ដោយសារខ្ញុំបានចេះចាំព្រះគម្ពីរ នៅក្នុងខួរក្បាលខ្ញុំ។ ខ្ញុំអាចបន្តរស់នៅជាគ្រីស្ទបរិស័ទ ដែលសកម្ម ប៉ុន្តែ តាមពិត ខ្ញុំរស់នៅសម្រាប់តែខ្លួនឯងសោះ។ សព្វថ្ងៃនេះ ខ្ញុំជាអ្នកជឿព្រះយេស៊ូវ តែខ្ញុំនៅតែមានការពិបាក នៅក្នុងការរស់នៅថ្វាយព្រះ ដោយសារភាពអាត្មានិយមរបស់ខ្ញុំ តែងតែទាក់ទាញអារម្មណ៍របស់ខ្ញុំ ឲ្យទៅធ្វើអំពើបាបជានិច្ច។ ដូចនេះ ខ្ញុំត្រូវតែបន្តឆែកពិនិត្យមើលខ្លួនឯង នៅចំពោះព្រះ ហើយបន្តអនុញ្ញាតឲ្យព្រះអង្គបន្តកែប្រែជីវិតខ្ញុំ ឲ្យក្លាយជាមនុស្សថ្មី តាមព្រះទ័យព្រះអង្គ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំជាកម្មសិទ្ធិរបស់ព្រះយេស៊ូវ ហើយការសុគតរបស់ព្រះអង្គបានបង់ថ្លៃលោះខ្ញុំ ឲ្យរួចពីបាប។ ខ្ញុំដឹងថា ព្រះអង្គនឹងនាំខ្ញុំចូលនគរស្ថានសួគ៌របស់ព្រះអង្គ ដោយសុវត្ថិភាព បន្ទាប់ពីខ្ញុំលាចាកលោកទៅ។


ការពិនិត្យមើល
ខ្លួនឯង
TESTING
OURSELVES

ដូចនេះ យើងអាចសួរខ្លួនឯងថា តើយើងអាចពិនិត្យមើលខ្លួនឯងដោយរបៀបណា? តើយើងពិនិត្យរកមើលអ្វីឲ្យពិតប្រាកដ?

សូមយើងពិនិត្យមើលចំណុចខាងក្រោមនេះ ដូចតទៅ :

**ទីមួយ យើងត្រូវពិនិត្យមើលទំនាក់ទំនងដែលយើងមានជាមួយព្រះ។** តើយើងមានចិត្តចង់ស្គាល់ព្រះអង្គទេ ឬយើងមានការធុញទ្រាន់ចំពោះព្រះអង្គ? សំណួរនេះបានធ្វើឲ្យខ្ញុំនឹកចាំ អំពីអាកប្បកិរិយាដែលខ្ញុំមាន ចំពោះសៀវភៅកត់ត្រាសេចក្ដីអធិស្ឋានរបស់មិត្តភក្តិខ្ញុំ ដែលបានបង្ហាញថា ខ្ញុំកំពុងតែមានទំនាក់ទំនងបែបណាជាមួយព្រះអង្គ។ កាលនោះ ខ្ញុំគិតថា ការអធិស្ឋាន គឺជាកិច្ចការដែលមិនចាំបាច់ ហើយខ្ញុំអាចស្គាល់ព្រះតាមមធ្យោបាយផ្សេងទៀតក៏បាន។

*ប៉ុន្តែ តាមពិត ការអធិស្ឋាន និងអានព្រះគម្ពីរ មានភាពចាំបាច់*
*លើសពីការនឹកស្មានរបស់យើង។ គឺតែងតែចាំបាច់ជានិច្ច។*

បានសេចក្ដីថា គ្រីស្ទបរិស័ទដែលបានជឿព្រះយូរជាងខ្ញុំ ក៏នៅតែត្រូវខិតខំអធិស្ឋាន និងអានព្រះគម្ពីរ គឺមិនខុសពីមនុស្សដែលត្រូវហាត់ប្រាណ និងបរិភោគជាទៀងទាត់ ដើម្បីឲ្យមានសុខភាពល្អនោះឡើយ។ បើយើងមិនមានចិត្តចង់ចូលទៅជិតព្រះ ហើយរស់នៅថ្វាយព្រះអង្គទេ នោះវាជាសញ្ញាគ្រោះថ្នាក់ហើយ។




**ទីពីរ យើងចាំបាច់ត្រូវពិនិត្យមើលទំនាក់ទំនង ដែលយើងមានជាមួយលោកិយ។** ត្រង់ចំណុចនេះ សំណួរដ៏សំខាន់នោះគឺ "តើខ្ញុំកំពុងតែព្យាយាមទៅឲ្យឆ្ងាយពីលោកិយ ឬកំពុងតែព្យាយាមរំដោះខ្លួនឲ្យរួចពីលោកិយ?" តើខ្ញុំកំពុងតែព្យាយាមរក្សាទុកភាពអាត្មានិយម ក្នុងចិត្តខ្ញុំឬ? មិត្តភក្តិរបស់ខ្ញុំម្នាក់ធ្លាប់ប្រាប់ខ្ញុំថា ការពោលពាក្យអសុរស ពេលយើងខឹង គឺមិនមែនជារឿងខុសឆ្គងអីទេ ព្រោះវាគ្រាន់តែជាពាក្យសម្តី ហើយបើសិនជាយើងមិនមានបំណងអាក្រក់ទេ នោះវាមិនខុសទេ(ទោះបទគម្ពីរអេភេសូរ ជំពូក ៤:២៩ បានហាមក៏ដោយ) ។ គាត់ថា ព្រះជាម្ចាស់ទតមើលចិត្តរបស់គាត់ទេតើ គឺមិនយកពាក្យសម្តីគាត់ជាសំខាន់នោះទេ។ តើខ្ញុំអាចប្រកែកជាមួយគាត់យ៉ាងដូចម្តេច? មិត្តភក្តិខ្ញុំបានលើកហេតុផល ដើម្បីការពារការពោលពាក្យអសុរោះ ដែលអាចធ្វើឲ្យអ្នកមិនជឿព្រះ មិនសប្បាយចិត្ត។

ដូចនេះ ខ្ញុំក៏សួរគាត់ថា *"ហេតុអ្វីអ្នកចាំបាច់ត្រូវដោះសារ? អ្នកដឹងថា វាជាពាក្យមិនល្អហើយ ហេតុអ្វីមិនជម្រុះវាចោល?"*

បញ្ហានៃការពោលពាក្យអសុរស គឺជាឧទាហរណ៍តូចមួយប៉ុណ្ណោះ។ តើយើងកំពុងតែព្យាយាមរក្សាទុកសេចក្ដីអាក្រក់ ក្នុងចិត្តយើង ដែលធ្វើឲ្យព្រះអម្ចាស់មិនសព្វព្រះទ័យឬ? យើងរាល់គ្នាសុទ្ធតែបានប្រព្រិត្តដូចនេះ ពីមួយពេលទៅមួយពេល ប៉ុន្តែ អ្នកដែលពិតជាចង់ដើរតាមព្រះយេស៊ូវ មិនអាចមានសន្តិភាពក្នុងចិត្តឡើយ បើសិនជាពួកគេស្រឡាញ់លោកិយ ខ្លាំងជាងព្រះនោះ។

**ទីបី យើងគួរតែពិនិត្យមើលទំនាក់ទំនង ដែលយើងមានជាមួយអ្នកដទៃ។** កាលខ្ញុំនៅរៀន ខ្ញុំមានសត្រូវម្នាក់។ នាងមានឈ្មោះឡូរី(Lori)។ នាងចូលចិត្តតាមធ្វើបាបខ្ញុំ ធ្វើឲ្យខ្ញុំស្អប់នាង។ បន្ទាប់ពីខ្ញុំបានទទួលជឿព្រះយេស៊ូវ អាកប្បកិរិយារបស់ខ្ញុំចំពោះឡូរី ក៏បានផ្លាស់ប្ដូរ។ តែវាមិនមានន័យថា ខ្ញុំឈប់ស្អប់គាត់នោះទេ។ … ខ្ញុំគ្រាន់តែមិនចង់ស្អប់គាត់ទៀត។ ខ្ញុំក៏បានអធិស្ឋាន តាមរបៀបដែលខ្ញុំមិនដែលអធិស្ឋានពីមុនមក។ ខ្ញុំបានទូលសូមឲ្យព្រះអង្គជួយខ្ញុំ ឲ្យស្រឡាញ់នាង។ នៅពេលយប់មួយ ខ្ញុំបានយល់សប្តិឃើញឡូរីក្លាយជាមិត្តល្អបំផុតរបស់ខ្ញុំ។ នៅថ្ងៃបន្ទាប់ ពេលខ្ញុំជួបគាត់នៅសាលារៀន ខ្ញុំក៏បានឈប់ស្អប់គាត់។ ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ដែលព្រះអង្គបាននាំឲ្យខ្ញុំទូលសូម និងបានជួយឲ្យខ្ញុំមានក្ដីស្រឡាញ់ចំពោះសត្រូវរបស់ខ្ញុំ។

ព្រះគម្ពីរបានចែងថា *"អ្នកណាដែលថា ខ្លួននៅក្នុងពន្លឺ តែស្អប់ដល់បងប្អូន នោះឈ្មោះថានៅក្នុងសេចក្ដីងងឹត ដរាបដល់សព្វថ្ងៃនេះ"* (១យ៉ូហាន ២:៩)។ ពេលណាយើងបានថ្វាយជីវិតយើងដល់ព្រះយេស៊ូវ នោះមិនមានន័យថា យើងនឹងឈប់មានសេចក្ដីអាក្រក់ក្នុងចិត្តយើងនោះឡើយ ប៉ុន្តែ បើយើងរក្សាទុកសេចក្ដីសម្អប់ ចំពោះអ្នកដទៃ ហើយគិតថា វាមិនមានអ្វីខុសទេ នោះវាជាសញ្ញាគ្រោះថ្នាក់មួយទៀតហើយ។


តើនរណា
ដឹកនាំជីវិតអ្នក?
WHO'S IN
CHARGE?

សរុបមក ចូរយើងសួរខ្លួនឯងថា "តើនរណាកំពុងដឹកនាំជីវិតខ្ញុំ?" តើយើងត្រូវសម្រេចចិត្តធ្វើអ្វីមួយ ដោយរបៀបណា? បើយើងគ្រាន់តែធ្វើតាមអារម្មណ៍ សុភាវគតិ ឬហេតុផលរបស់យើងទេ នោះមានន័យថា យើងមិនបានឲ្យព្រះយេស៊ូវដឹកនាំជីវិតយើងទេ។ ក្នុងនាមខ្ញុំជាសិល្បៈករវ័យក្មេងម្នាក់ ខ្ញុំតែងតែចង់ទៅមើលវិទ្យាស្ថានសិល្បៈ នៅទីក្រុងឈីកាហ្គោ។ ថ្ងៃមួយគ្រូសិល្បៈរបស់ខ្ញុំបានមកជួបខ្ញុំ ហើយនិយាយថា គាត់ចង់បញ្ជូនឈ្មោះខ្ញុំចូលផ្នែកមួយ ក្នុងសាលារៀននោះ។ បន្ទាប់ពីខ្ញុំបានអធិស្ឋាន សូមព្រះអង្គដឹកនាំការសម្រេចចិត្តនោះ(កាលនោះខ្ញុំទើបតែទទួលជឿព្រះយេស៊ូវ) ខ្ញុំក៏បានប្រាប់គាត់ថា ខ្ញុំបានសម្រេចចិត្តមិនទៅរៀននៅទីនោះ។ ខ្ញុំដឹងថា នៅមហាវិទ្យាល័យនោះ មានការល្បួងច្រើនពេកសម្រាប់ខ្ញុំ។ ម្យ៉ាងទៀតខ្ញុំបានទទួលការប៉ះពាល់ចិត្ត ឲ្យចង់បម្រើព្រះ តាមរបៀបផ្សេងមួយទៀត។ អាកប្បកិរិយារបស់ខ្ញុំ ក៏បានផ្លាស់ប្តូរទាំងស្រុង ហើយខ្ញុំក៏បានទៅរៀននៅសាលាព្រះគម្ពីរវិញ ដើម្បីរៀបចំខ្លួន សម្រាប់ការរស់នៅជាបេសកជន នៅក្រៅប្រទេស។ ទិសដៅនៃជីវិតខ្ញុំ ត្រូវបានព្រះជាម្ចាស់កំណត់ ដូចនេះ ខ្ញុំមិនត្រូវឲ្យក្តីប្រាថ្នារបស់ខ្ញុំ ដឹកនាំជីវិតខ្ញុំឡើយ។ អ្វីដែលគួរឲ្យអស់សំណើចនោះគឺ ពេលដែលខ្ញុំបានទៅរៀននៅសាលាព្រះគម្ពីរ ខ្ញុំក៏បានរៀនបណ្តើរ ហើយរកប្រាក់ចំណូលបណ្តើរ តាមរយៈការគូរគំនូរ។




**សរុបមក សំណួរសំខាន់បំផុត** គឺជាសំណួរដែលព្រះយេស៊ូវបានសួរពួកសិស្សព្រះអង្គថា *"តើអ្នករាល់គ្នាថា ខ្ញុំជាអ្នកណា?"* (ម៉ាកុស ៨:២៩)។ ព្រះអង្គមិនបានសួរថា *"តើពួកជំនុំថាខ្ញុំជានរណា?"* *"តើឪពុកម្ដាយរបស់អ្នកថា ខ្ញុំជានរណា?"* ឬ "តើមិត្តភក្តិរបស់អ្នកថា ខ្ញុំជានរណា?" តែព្រះអង្គបានសួរពួកសិស្សរបស់ព្រះអង្គ ដើម្បីឲ្យពួកគេឆ្លើយចេញពីចិត្ត ផ្ទាល់ៗខ្លួនថា ព្រះអង្គជានរណា។ ព្រះអង្គក៏សួរសំណួរនេះ មកយើងម្នាក់ៗផងដែរ។ ដូចនេះ តើអ្នកថា ព្រះអង្គជានរណា? បន្ទាប់ពីអ្នកបានអានរឿងរបស់ព្រះអង្គ ក្នុងព្រះគម្ពីរប៊ីបហើយ តើអ្នកថា ព្រះអង្គជានរណា?

ការចម្រើនវ័យធំឡើង ក្នុងនាមជាអ្នកទៅព្រះវិហារ អាចជារឿងដ៏ប្រសើរ។ ប៉ុន្តែ វាក៏មានបញ្ហាប្រឈមផងដែរ។ ខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យស្វែងយល់អំពីព្រះយេស៊ូវដោយផ្ទាល់ខ្លួន។ សូមកុំឲ្យពេលវេលាកន្លងផុតទៅ ដោយមិនបានស្គាល់ព្រះអង្គច្បាស់នោះឡើយ។

បើសិនជាអ្នកចង់ស្វែងយល់បន្ថែមអំពីព្រះយេស៊ូវ និងអំពីការអ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នក យើងខ្ញុំមានកូនសៀវភៅជាច្រើនទៀត ដែលនឹងឆ្លើយសំណួរធំៗ ដូចជា: តើព្រះយេស៊ូវជានរណា? តើយើងពិតជាអាចជឿព្រះគម្ពីរឬទេ? ដើម្បីទាញយក ឬ Download ដោយឥតគិតថ្លៃ សូមចូលទៅតាម link: https://khmer-odb.org/ds/

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក សុខ គីម

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2020 ODB Ministries (website: www.odb.org)

ចេញផ្សាយដោយ : ODB Cambodia (email: cambodia@odb.org, Tell: 087 233 907,

website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb)